សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០២ លេខ ២៤២ ចេញផ្សាយថ្ងៃ សុក្រ ទី ១២ ខែ កញ្ញា ឆ្នាំ ២០០៨

## សហភាពសហជីពកម្ពុជាទូលសុំព្រះមហាក្សត្រប្រើព្រះរាជសិទ្ធិ របស់ព្រះអង្គដោះស្រាយបញ្ហាសៀមឈ្លានពានទឹកដីខ្មែរ


សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រកម្ពុជា


លោក រ៉ុង ឈុន ប្រធានសហភាពសហជីពកម្ពុជា


ប្រាសាទព្រះវិហារជាកេរមរតកដ៏មានតម្លៃរបស់ជាតិខ្មែរ


ប្រាសាទតាមាន់ស្ថិតនៅក្នុងមហិច្ឆតារបស់ពួកឈ្លានពានសៀម

ដោយ : មាឡា ឧត្តម

សហភាពសហជីពកម្ពុជា ដែលដឹកនាំដោយលោក *រ៉ុង ឈុន* បានទូលសុំព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* ព្រះមហាក្សត្រខ្មែរដើម្បីព្រះអង្គប្រើប្រាស់ព្រះរាជសិទ្ធិរបស់ព្រះអង្គ ស្របតាមរដ្ឋធម្មនុញ្ញសម្រាប់ធ្វើការដោះស្រាយបញ្ហាសៀមឈ្លានពានទឹកដីខ្មែរ។

តទៅទំព័រ៤ ម

## សម រង្ស៊ី ថា ព្រះមហាក្សត្រគ្មានអំណាចទេ និងធ្វើអ្វីៗតាមការចង់បាន របស់គណបក្សប្រជាជន


លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី


លោក កឹម សុខា

ដោយ : ស្សាទរីយ៍

លោក*សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី និងលោក*កឹម សុខា* ប្រធាន គណបក្សសិទ្ធិមនុស្ស បានបញ្ជាក់ជំហររួមគ្នា នៅទីក្រុងប៉ារីសប្រទេសបារាំង ឆ្លើយតប ទៅនឹងព្រះរាជសារ កោះប្រជុំរបស់ព្រះមហាក្សត្រ

តទៅទំព័រ២ ស

## ចោរសៀមឈ្លានពាននៅតែព្យាយាម បញ្ចូញចង្កូមដាក់ខ្មែរយ៉ាងតឃ្លើនបំផុត


ឧត្តមសេនីយ៍ អានុពង្ស ប៉ៅចិន្តា


ទិដ្ឋភាពនៅច្រកចេញចូលប្រាសាទតាមាន់ធំកាន់កាប់ដោយទាហានសៀម

ដោយ : វិសាល

ទោះបីជាស្ថានការណ៍នយោបាយនៅក្នុងប្រទេសសៀមមានភាពវឹកវរយ៉ាងណាក៏ដោយ ក៏ទាហានសៀមឈ្លានពាននៅតែព្យាយាមបញ្ចេញចង្កូមដាក់ខ្មែរ ដោយគ្មានការកោតញញើតអ្វីទាំងអស់។

តទៅទំព័រ២ ច

## សមាជិកគណៈរដ្ឋមន្ត្រីថ្មី ត្រៀមជប់លៀងឱ្យកក្រើកភ្នំពេញ


លោក ហ៊ុន សែន និងក្រុមមន្ត្រីក្រោមឱវាទ

ដោយ : រតនៈ

រដ្ឋសភា និងរាជរដ្ឋាភិបាលកញ្ចប់ គ្រោងចេញជារូបរាងហើយ បើទោះបីជាការប្រជុំសភាដំបូង មិនគ្រប់១២០រូប តាមមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល របស់ប្រទេសក៏ដោយ។ មួយថ្ងៃបន្ទាប់

តទៅទំព័រ២ គ

## សុន ឆ័យ ថា តម្លៃប្រេងនៅកម្ពុជាគួរបញ្ចុះ ត្រឹម៣.៨០០រៀលក្នុងមួយលីត្រ


លោក សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ


ប្រេងសាំងនៅកម្ពុជានៅតែមានតម្លៃខ្ពស់ជាងទីផ្សារអន្តរជាតិ

ដោយ : សច្ចៈ

តម្លៃប្រេងឆៅ នៅលើទីផ្សារពិភពលោក បានបញ្ចុះថ្លៃយ៉ាងគំហុក រយៈពេលប៉ុន្មានខែចុងក្រោយនេះ គឺនៅក្នុងខែមិថុនា២០០៨ តម្លៃជាង១៤៨ ដុល្លារក្នុងមួយធុង ឬមួយបារ៉ែល ចុះនៅត្រឹមតែ៩៩.៣០ ដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងមួយធុង កាលពីថ្ងៃទី៩ កញ្ញា ២០០៨ ។ ការចុះថ្លៃនេះ បាន

តទៅទំព័រ៤ ន

## សហគមន៍កសិករនៅបត់គគីរគ្មានជំនឿលើ ស្បោង សារ៉ាត ទើបនាំគ្នាអំពាវនាវឱ្យ ហ៊ុន សែន និងភរិយាជួយអន្តរាគមន៍


រដ្ឋលេខាធិការ ប្រាក់ សុខុន


រដ្ឋមន្ត្រី ម៉ុក ម៉ារ៉េត


លោក ស្បោង សារ៉ាត មេគណបក្សប្រជាជនក្រុងព្រះសីហនុ

ដោយ : ជ.ឧត្តម

ដោយសារតែគ្មានជំនឿទៅលើលោក*ស្បោង សារ៉ាត* ដែលជាចៅហ្វាយក្រុងព្រះសីហនុ និងជាឪពុកក្មេករបស់ថៅកែក្រុមហ៊ុនហេងប៊ុនណាត ខូអិល ធីឪនោះហើយទើបប្រជាកសិករ នៅសហគមន៍បត់គគីរ សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ បាននាំគ្នាអំពាវនាវយ៉ាងទទូចទៅលោក*ហ៊ុន សែន*និងភរិយា

តទៅទំព័រ៣ ខ

## មេដឹកនាំបក្សប្រឆាំង ទាំងពីរបញ្ជាក់ជំហរដូចគ្នា

ដោយ : គ.អរពិន្ទ

លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ី និងលោក *កឹមសុខា* ប្រធានគណបក្សសិទ្ធិមនុស្សដែលកំពុងរួមគ្នាធ្វើការតវ៉ានៅក្រៅប្រទេស និងកំពុងស្ថិតនៅក្នុងទីក្រុងប្រ៊ុចសែលជាផ្នែកនៃការតវ៉ាចំពោះលទ្ធផលឆ្នោតនៅកម្ពុជានោះ បានប្រកាសបញ្ជាក់ថា លោក និងសមាជិកសភារបស់លោកទាំងពីរគណបក្សនឹងមិនចូលរួមស្បថក្នុងការប្រជុំសភាថ្ងៃដំបូងនោះទេ។

លោក *សម រង្ស៊ី*និងលោក *កឹម សុខា* បានរួមគ្នាសម្តែងជំហរនេះក្នុងបទសម្ភាសន៍ជា

តទៅទំព័រ៣ ឃ

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លឹម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ដុំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់អ្លល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បែត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លឹម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្ពាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616,

*បរិយាយថ្ងៃនេះ*

## បញ្ហាទំនាស់ដីធ្លីនៅតែក្តៅគគុក អាចក្លាយទៅជាឈ្លួនផ្ទុះបដិវត្តន៍ដីធ្លី

ដោយ : មាឡា ច្រាថ្នា

គណបក្សប្រជាជនបានសម្រេចផែនការរបស់ខ្លួនក្នុងការប្រើប្រាស់ គ.ជ.ប ជាឧបករណ៍ឃុបឃិតជាមួយអាជ្ញាធរដែនដីក្រោមការត្រួតត្រារបស់ខ្លួនដើម្បីលួចប្លន់សន្លឹកឆ្នោតប្រជារាស្ត្រដើម្បីបំប៉ោងតួលេខ ក៏ដូចជាបំភ្លៃលទ្ធផលឱ្យគណបក្សនេះបានអាសនៈសភាដល់ទៅ៩០ហួសពីប្រជាប្រិយភាពរបស់ខ្លួន។ ប៉ុន្តែជាមួយគ្នានេះ ដែលគេមើលឃើញថា

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ខ**

ចំណែកភាគីខ្មែរយើងឯណេះវិញ គឺនៅតែឱនលំទោនគោរពអនុស្សារណៈយោគយល់គ្នាតាំងពីសម័យ *ថាក់ស៊ីន* កាន់អំណាច ដោយមិនហ៊ានធ្វើការតបតតាមផ្លូវច្បាប់ណាមួយ ដើម្បីឱ្យចោរសៀមឈ្លានពានទឹកដីខ្មែរបានភ្លឹកភ្លែកម្តងណាឡើយ ។

ជាក់ស្តែងពួកចោរសៀមបានបង្កើនកងទ័ពនៅតំបន់ព្រំដែនជប់អង្គុញ ដែលស្ថិតនៅក្នុងភូមិសាស្រ្តភូមិថ្មដូន ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ និងបានរារាំងទាហានខ្មែរយើងមិនឱ្យដើរល្បាតលើផ្លូវឆ្លងកាត់ទីនោះថែមទៀតផង ។

ការរាំងដោយទាហានសៀមឈ្លានពានបែបនេះ គឺដូចជាធ្វើឱ្យដាច់ផ្លូវធ្វើដំណើរតាមព្រំដែនពីច្រកថ្មដូនទៅប្រាសាទតាក្របីក្នុងចម្ងាយប្រមាណជាង១០គីឡូម៉ែត្រយ៉ាងដូច្នោះដែរ ។ នេះបើតាមសេចក្តីរាយការណ៍ព័ត៌មានពីស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។

លោកវរសេនីយ៍*ស៊ុម សុខា* មេបញ្ជាការរងកងការពារព្រំដែនលេខ៤០២ បាននិយាយកាលពីរសៀលថ្ងៃទី១០ ខែកញ្ញា ថា ស្ថានការណ៍ជម្លោះព្រំដែនពីចន្លោះច្រកថ្មដូន ទៅប្រាសាទតាក្របីកំពុងស្ថិតក្នុងសភាពធ្ងន់ធ្ងរទៅៗហើយ ដោយសារទាហានឈុតខ្មៅសៀមបានបង្កើនចំនួនប្រមាណ៧០នាក់ឯណោះ ។ ហើយទាហានឈុតខ្មៅសៀមទាំងនោះប្រដាប់ដោយអាវុធគ្រប់ដៃបាននាំគ្នាមកបោះទីតាំងឈរជើងនៅជប់អង្គុញត្រង់ចំណុចជប់ត្រឡោកយ៉ាងខែងរ៉ែងបំផុត ។

លោកវរសេនីយ៍រូបនេះបានបន្តទៀតថា "*ទាហានសៀមទាំងនោះបានជីកលេណដ្ឋាន, សង់ជំរុំធ្វើជាទីជម្រក និងហ៊ានទៅរារាំងទាហានខ្មែរយើងមិនឱ្យដើរល្បាតតាមផ្លូវថ្មើរជើង និងផ្លូវគោយន្តបានលើខ្នងភ្នំដងរែកឆ្លងកាត់ចំណុចព្រំដែនជប់អង្គុញទៀត*" ។

យ៉ាងណាក៏ដោយ លោកវរសេនីយ៍ *ស៊ុម សុខា* បានឱ្យដឹងថា ប្រការដែលទាហានសៀមធ្វើដោយគឃ្លើនយ៉ាងដូច្នេះ ទំនងគេចង់សាកល្បងធ្វើជាលេសថ្មីមួយទៀតក្នុងការបង្កទំនាស់ជាមួយកម្ពុជា ។ ព្រោះមុននេះបន្តិចខាងទាហានខ្មែរយើងធ្លាប់បានហាមឃាត់ទាហានឈុតខ្មៅសៀមចំនួន៣នាក់មិនឱ្យស្ពាយកាំភ្លើងចូលប្រាសាទតាក្របី ។

យោងតាមហេតុផលនេះហើយទើបនៅចំណុចព្រំដែនជប់អង្គុញនោះ ក៏មានទាហានខ្មែរច្រើនដែរនិងមានជីកលេណដ្ឋានសង់ជំរុំធ្វើជាទីជម្រកយ៉ាងមាំទាំថែមទៀតផង ។

មន្ត្រីយោធាជាន់ខ្ពស់មួយរូបបានថ្លែងថា "*ទាហានសៀមនិងទាហានខ្មែរបានរាយបណ្តាក់គ្នាពីចន្លោះថ្មដូន ទៅប្រាសាទតាក្របី ។ ដូច្នេះភាពតានតឹងកំពុងតែកើតមានហើយ ខណៈដែលទាហានឈុតខ្មៅសៀមទាំងនោះបានកាត់ផ្តាច់ផ្លូវដើរល្បាតតាមព្រំដែននៅជប់អង្គុញនោះ*" ។

កន្លងមកនរណាៗក៏ដឹងដែរថា ក្រៅពីតំបន់ប្រាសាទព្រះវិហារគឺមានតែប្រាសាទតាមាន់តូច និងប្រាសាទតាមាន់ធំប៉ុណ្ណោះដែលទាហានសៀមមានមហិច្ឆតាច្បាមយកធ្វើជាមរតករបស់ខ្លួននោះ ។ ប៉ុន្តែឥឡូវនេះមហិច្ឆតាមិនស្កប់ស្កល់របស់ចោរសៀមឈ្លានពានគឺមានគោលដៅប្លន់យកប្រាសាទតាក្របីទៀតហើយ ។

មានសេចក្តីរាយការណ៍ដាច់ដោយឡែកមួយបានឱ្យបណ្តាញព័ត៌មានដឹងថា មានទាហានឈុតខ្មៅសៀមជាច្រើននាក់ប្រដាប់ដោយអាវុធគ្រប់ដៃបានព្យាយាមចូលកាន់កាប់ប្រាសាទតាក្របីទាំងកម្រោល តែត្រូវទាហានខ្មែរទប់ស្កាត់ទាន់ពេលវេលា ។

ចំណែកសភាពការណ៍នៅឯប្រាសាទតាមាន់ធំវិញគឺទាហានសៀមនៅតែធ្វើជាម្ចាស់ទ្វាររបងចេញចូលប្រាសាទនេះដដែល ដោយគ្មានអ្វីអាចប្តូរផ្លាស់សភាពការណ៍នេះបានឡើយ ។

ក្រុមអ្នកសង្កេតការណ៍នានាបាននិយាយថា នៅពេលដែលរដ្ឋាភិបាលក្រុងភ្នំពេញប្រកាន់យកនូវជំហរចរចាទ្វេភាគីជាមួយរដ្ឋាភិបាលក្រុងបាងកកនោះ គឺការចរចានេះកាន់តែអូសបន្លាយវែងឆ្ងាយតទៅទៀតហើយ ។ ព្រោះ *សាម៉ាក់ ស៊ុនដារ៉ាវេត* នាយករដ្ឋមន្ត្រីសៀមបានធ្លាក់ពីអំណាចក្រោមការសម្រេចនៃតុលាការធម្មនុញ្ញសៀម ។

ម្យ៉ាងទៀតក្រុមបាតុករប្រឆាំងនឹង *សាម៉ាក់ ស៊ុនដារ៉ាវេត* បានប្រកាសយ៉ាងកងរំពងថា ការធ្វើបាតុកម្មនៅតែបន្តធ្វើរហូតដល់នាយករដ្ឋមន្ត្រីថ្មីបានឡើងកាន់អំណាច ។ ហើយបើនាយករដ្ឋមន្ត្រីថ្មីនោះជាសែស្រឡាយរបស់ *សាម៉ាក់* ឬ *ថាក់ ស៊ីន* ទៀត គឺពួកគេនឹងបន្តធ្វើបាតុកម្មដោយគ្មានទីបញ្ចប់ឡើយ ។

គួរបញ្ជាក់ថា សូម្បីតែរដ្ឋមន្ត្រីការបរទេសសៀមដែលជាដៃគូចរចាជាមួយរដ្ឋមន្ត្រីការបរទេសខ្មែរនោះ ក៏រដ្ឋាភិបាលសៀមជ្រើសរើសមិនទាន់បានផង ហើយឥឡូវនេះនាយករដ្ឋមន្ត្រីសៀមត្រូវតុលាការធម្មនុញ្ញសៀមបញ្ចប់អំណាចយ៉ាងតក់ក្រហល់ទៀត តើការចរចានឹងត្រូវអូសបន្លាយដល់ពេលណា ?

តាមពិតទៅអ្វីដែលជាការចរចាកន្លងមក រវាងភាគីខ្មែរនិងភាគីសៀមពុំមានលេចចេញនូវលទ្ធផលដុំកំភួនទាល់តែសោះ ពោលគឺចោរសៀមឈ្លានពាននៅតែបន្តការបង្កើនកងទ័ពក្នុងន័យបញ្ចេញចង្កូមដាក់ខ្មែរជារៀងរហូតដែលធ្វើឱ្យខ្មែររស់នៅមិនបានសុខឡើយ ។

រហូតមកដល់ពេលនេះគេមិនដឹងថា រដ្ឋាភិបាលកញ្ចប់របស់លោក *ហ៊ុន សែន* នឹងត្រូវគិតគូរដោះស្រាយដោយវិធីណាទៀតនោះទេព្រោះសាធារណៈមតិជាទូទៅធ្លាប់បានលើកឡើងក្នុងន័យជម្រុញឱ្យរដ្ឋាភិបាលខ្មែរនេះត្រូវតែប្តឹងទៅអង្គការសហប្រជាជាតិ ឬតុលាការអន្តរជាតិ ដើម្បីបញ្ចប់អំពើឈ្លានពានរបស់ចោរសៀមឱ្យបានឆាប់រហ័ស តែប្រមុខរដ្ឋាភិបាលខ្មែរមិនបានយកត្រចៀកស្តាប់ឡើយហើយ នៅតែប្រកាសយ៉ាងដាច់ណាត់ថា នឹងបន្តការចរចាទ្វេភាគីនេះទៀត ។

ទីបំផុតការចរចាទ្វេភាគីត្រូវបានផ្អាកដោយគ្មានការកំណត់ ដែលធ្វើឱ្យភាគីខ្មែរដែលជាភាគីរងគ្រោះនៅតែបន្តការទទួលរងគ្រោះដោយគ្មានពេលកំណត់ដែរតើមិនឱ្យប្រជាពលរដ្ឋខ្មែរឈឺចាប់យ៉ាងដូចម្តេចបាន ?៕

**តមកពីទំព័រ១ គ**

ឬលើសតិចតួចនោះលោក*ហ៊ុន សែន* នឹងជម្រុញឱ្យបង្កើត រដ្ឋសភា និងរាជរដ្ឋាភិបាលកញ្ចប់ចេញឱ្យឆាប់ ដើម្បីគាត់បានធ្វើជានាយករដ្ឋមន្ត្រី ។

សមាជិកគណៈរដ្ឋមន្ត្រី នៃរដ្ឋាភិបាលកញ្ចប់ ដែលឈ្មោះនៅក្នុងបញ្ជីប្រកាសអោយដឹងកាលពីថ្ងៃទី២៩កក្កដា ២០០៨ បានឱ្យដឹងថា មានរហូតដល់ទៅជាង៤០០នាក់ ដែលនេះនៅមិនទាន់គិតបញ្ចូល សមាជិកគណៈរដ្ឋមន្ត្រីកូតាគណបក្សហ៊្វុនស៊ិនប៉ិចនៅឡើយ ។

សេចក្តីរាយការណ៍ បានឱ្យដឹងថា សមាជិកគណៈរដ្ឋមន្ត្រីខ្លះ ពិសេសពួកផ្តាច់ខ្លួនពីគណបក្សសម រង្ស៊ី បានត្រៀមធ្វើពិធីជប់លៀង ឱ្យកក្រើកក្រុងភ្នំពេញ បន្ទាប់ពីពួកគេ ត្រូវបានរដ្ឋសភា បោះឆ្នោតលើកដៃជាផ្លូវការ ។ ការត្រៀមធ្វើពិធីជប់លៀងនេះ ស្របពេលដែល ទាហានឈុតខ្មៅសៀមបានបន្តឈ្លានពាន ចូលបូរណភាពទឹកដីខ្មែរជាបន្តបន្ទាប់ ដូចជាតំបន់ក្បែរជើងភ្នំ ប្រាសាទព្រះវិហារ, ប្រាសាទតាមាន់ធំ, ប្រាសាទតាក្របី និងតំបន់ជប់គគីរខាងកើត ក្នុងអាណាចក្រឧត្តរមានជ័យជាដើម ។

សមាជិកគណៈរដ្ឋមន្ត្រីថ្មី នៃរដ្ឋាភិបាលកញ្ចប់ អាណត្តិទី៤ នេះត្រូវបានគេដឹងថាមានចំនួនច្រើនហួសហេតុ បង្កើតឡើងបង្ហិនថវិកាជាតិ ។ ផ្ទុយទៅវិញ រដ្ឋាភិបាលថ្មី នៅតែបង្ហាញអំពីការមិនយកចិត្តទុកដាក់ចំពោះបញ្ហាបូរណភាពទឹកដី បើកដៃឱ្យចោរសៀម ឈ្លានពានតាមចិត្តនៅព្រំដែន ។

លោក*ហ៊ុន សែន* បានតែងតាំងទីប្រឹក្សាច្រើន ដែលគ្រាន់តែបង្ហិនថវិកាជាតិ ហើយនៅពេលប្រទេសមានអាសន្ន ជួបបញ្ហាចោរប្រទេសជិតខាងប្លន់ទឹកដី បែរជាគ្មានប្រាក់ គ្មានស្បៀងឱ្យកងទ័ព ។ ជាងនេះទៅទៀតនោះគឺសមាជិកគណៈរដ្ឋមន្ត្រី ពិសេសខ្សែលោក*ហ៊ុន សែន* បានត្រៀមជប់លៀងឱ្យកក្រើកក្រុងភ្នំពេញហើយ នាពេលឆាប់ៗនេះ ពិសេសនៅក្រោយការបង្កើត រដ្ឋាភិបាលកញ្ចប់រួចរាល់ ។

ភាពសប្បាយហ៊ឺហា ស្របពេលដែលប្រទេសជាតិ កំពុងទទួលរងពីការឈ្លានពានរបស់ចោរសៀមនេះ បានបង្ហាញឱ្យឃើញថា គណបក្សប្រជាជនមិនខ្វល់នឹងបូរណភាពទឹកដីទេ ពិសេសព្រំដែនខាងលិច ដែលឮជារៀងរាល់ថ្ងៃថាចោរឈ្លានពានសៀមបានរំលោភចូលក្នុងដីខ្មែរយ៉ាងងងើលនោះ ។

ដោយសារគិតតែ ពីភាពសប្បាយមិនខ្វល់អំពីបូរណភាពទឹកដីនេះហើយ បានជាចោរឈ្លានពានសៀម បន្តរំលោភចូលក្នុងទឹកដីខ្មែរ ដោយគ្មានញញើត និងពិសេសនោះ នៅពេលដែលចោរសៀម ឮសម្តីប្រមុខរដ្ឋាភិបាល*ហ៊ុន សែន*ថា ឱ្យកងទ័ពខ្មែរអត់ធ្មត់ ។

មានសេចក្តីរាយការណ៍ ពីប្រាសាទតាក្របីបានអោយដឹងថា កាលពីល្ងាចថ្ងៃពុធកងទ័ពខ្មែរយើង ទប់កំហឹងមិនបានក៏បានបាញ់កាំភ្លើងឡើងលើមួយគ្រាប់ ជាការព្រមានមិនអោយទាហានសៀម ជាង១០០នាក់ចូលឈ្លានពាន ប្រាសាទតាក្របីរបស់ខ្មែរ ។

មតិនានា សំដែងការកោតសរសើរទាហានខ្មែរយើងដែលហ៊ានផ្ទុះអាវុធ គំរាមពួកចោរសៀមនេះ បើទោះបីជាក្រុមចោរហារយទាំងនោះ មិនខ្លាចក៏ដោយ ។ ប៉ុន្តែបើសិនជាកងទ័ពខ្មែរ ដែលស្រឡាញ់ជាតិជាងជីវិតខ្លួននោះ បាញ់ចំពួកឈ្លានពានសៀម ប្រាកដជាប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* បញ្ជាឱ្យមន្ត្រីក្រោមឱវាទដកបញ្ឈរជើងជាមិនខាន ដូចករណីមេទ័ពពិការជើងទាំងពីរ ឈ្មោះ *យួន វណ្ណា* ប្រចាំការនៅតំបន់

**តទៅទំព័រ៣ គ**

**តមកពីទំព័រ១ ស**

សម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* នៅថ្ងៃដំបូង ដែលគ្រោងនឹងធ្វើ នៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ ។

ទាំងលោក*សម រង្ស៊ី* ទាំងលោក*កឹម សុខា* បានបញ្ជាក់ថា សមាជិកសភានៃគណបក្សទាំងពីរ ចំនួន២៩រូប នឹងមិនចូលស្បថ នៅថ្ងៃទី២៤ កញ្ញា ២០០៨ទេ ហើយអាចនឹងចូលស្បថ នៅថ្ងៃបន្ទាប់ឬប៉ុន្មានថ្ងៃក្រោយពីការចូលស្បថ របស់សមាជិកគណបក្សប្រជាជន ។ ជាមួយគ្នានោះដែរ លោក*សម រង្ស៊ី* បានហៅព្រះរាជសារ ព្រះមហាក្សត្រ កាលពីថ្ងៃទី៨ ខែកញ្ញា ២០០៨ថា ព្រះអង្គគ្មានអំណាចនិងធ្វើអ្វីៗទៅតាមការចង់បាន របស់គណបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះ ។

ផ្តល់បទសម្ភាសន៍រួមគ្នា ឱ្យវិទ្យុបារាំងអន្តរជាតិនៅទីក្រុងប៉ារីស ប្រទេសបារាំង កាលពីល្ងាចថ្ងៃពុធ ទី១០ កញ្ញា ឆ្នាំ ២០០៨ លោក*សម រង្ស៊ី* បានមានប្រសាសន៍ថា "*គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សមានគោលជំហរជាមួយគ្នា គឺយើងមិនទទួលស្គាល់នៃលទ្ធផលបោះឆ្នោតទេ ។ ដូច្នេះយើងមិនចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ ពីព្រោះបើយើងចូលប្រជុំ គឺបានន័យថាយើងទទួលស្គាល់ យើងប្រថាប់ត្រា ប៉ុន្តែយើងចូលរួមនៅពីរបីថ្ងៃបន្ទាប់ពីពួក គេបានចូលប្រជុំលើកទីមួយ*" ។

ពាក់ព័ន្ធទៅនឹងព្រះរាជសារកោះប្រជុំលើកដំបូង របស់ព្រះករុណានេះដែរលោក*កឹម សុខា* បានថ្លែងទល់មុខគ្នាជាមួយនឹងលោក*សម រង្ស៊ី*ថា "*យើងមានគោលជំហររួមដូចគ្នាគណបក្សសម រង្ស៊ីដែរ គឺតំណាងរាស្ត្រទាំង៣រូប របស់គណបក្សសិទ្ធិមនុស្ស មិនអាចចូលរួមប្រជុំនៅថ្ងៃទី២៤ កញ្ញាបានទេ*" ។

នៅពេលដែលសួរថាបើសិនជាមិនចូលរួមប្រជុំនៅថ្ងៃដំបូងតាមការត្រាស់បង្គាប់ របស់ព្រះមហាក្សត្រទេដូចមានន័យថា គណបក្សទាំងពីរ មិនគោរពច្បាប់ ? លោក*សម រង្ស៊ី* បានមានប្រសាសន៍ថា "*វាមិនមែនអ៊ីចឹងទេ ព្រះមហាក្សត្រលោកអត់មានអំណាចអីទេនៅប្រទេសកម្ពុជា ។ អ្វីដែលគណបក្សប្រជាជនស្នើ គឺព្រះមហាក្សត្រតែងតែធ្វើតាម, ហើយបើគណបក្សប្រជាជន មិនអនុញ្ញាតឱ្យធ្វើទេ ព្រះមហាក្សត្រក៏មិនហ៊ានធ្វើដែរ ដូចជាការលើកលែងទោសថ្វាយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ គឺចាំភ្លើងខៀវ ពីថ្នាក់ដឹកនាំគណបក្សប្រជាជនសិន ។ដូច្នេះរឿងនេះ វាមិនគោរព ឬគោរពព្រះមហាក្សត្រទេ គឺយើងត្រូវគោរពសម្បជញ្ញៈរបស់យើង, បើសម្បជញ្ញៈរបស់យើង មិនឱ្យចូលរួមនៅក្នុងសភាមួយ ដែលយើងចាត់ទុកថា ជាសភាចោរ ជាសភាខ្មោច ជាសភាយួន ។ ចោរគឺលួច,ខ្មោចគឺឈ្មោះខ្មោចគេប្រើប្រាស់ ដើម្បីឱ្យទៅបោះឆ្នោត ជូនគណបក្សប្រជាជន, គេអោយជនជាតិបរទេសបោះឆ្នោតបន្លំធ្វើជាខ្មែរ ។ ដូច្នេះសភាចោរ សភាខ្មោចនិងសភាយួន, គណបក្សសម រង្ស៊ីអត់ចូលរួមទេ*" ។

ចំពោះការសរសេរលិខិតស្នើទៅព្រះអង្គមហាក្សត្រចូលរួមស្បថដោយឡែកនោះ លោក*កឹម សុខា* បានមានប្រសាសន៍ថា "*យើងបានផ្ញើលិខិត ដាច់ដោយឡែកៗពីគ្នា ស្នើទៅព្រះមហាក្សត្រប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតប ។ រហូតមកដល់ពេលនេះ យើងនៅតែរង់ចាំចម្លើយរបស់ព្រះអង្គ... ។ ចំពោះព្រះអង្គ ត្រាស់បង្គាប់ឱ្យចូលរួមប្រជុំនោះ... យើងនៅតែរង់ចាំចម្លើយសិន*" ។

ទាក់ទង ទៅនឹងអ្នកសង្កេតការណ៍បោះឆ្នោត ពីប្រទេសជប៉ុន និងស្ថានទូតអាមេរិកប្រចាំក្រុងភ្នំពេញ អះអាងថាការបោះឆ្នោតលើកនេះ ល្អប្រសើរជាងមុនៗនោះលោក*សម រង្ស៊ី* បានមានប្រសាសន៍ថា "*សហភាពអឺរ៉ុបបានចេញសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោត នៅស្រុកខ្មែរ កាលពីពេលថ្មីៗនេះ វាមិនបានគោរព ស្តង់ដារអន្តរជាតិ...*" ។ ចំពោះពាក្យដែលគេថា វាគ្រាន់បើជាងមុននោះ លោក*សម រង្ស៊ី* បានមានប្រសាសន៍ថា "*គ្រាន់បើជាងមុននោះគឺគ្រាន់តែមានការសម្លាប់តិចជាងមុន ។ ប៉ុន្តែទោះបីជាមានការបង្ហូរឈាមតិចជាងមុនក៏ដោយ តែការលួចបន្លំសន្លឹកឆ្នោតមានច្រើនជាងមុន ។ អ្វីដែលហៅថា គ្រាន់បើជាងមុន អ្វីដែលហៅថា យ៉ាប់ជាងមុន អាក្រក់ជាងមុន ។ ដូច្នេះមានល្អជាងមុនខ្លះ, ហើយវាមានអាក្រក់ជាងមុនច្រើនមានន័យថា អត់មាននរណាគេទទួលស្គាល់លទ្ធផលបោះឆ្នោតពេញលេញទេ ដូចជារដ្ឋាភិបាលបារាំង អត់មានផ្ញើលិខិតអបអរសាទរ នឹងលទ្ធផលនៃការបោះឆ្នោត ចំពោះគណបក្សណា... ដើម្បីសរសើរនោះទេ... ។ សព្វដង គ្រាន់តែគ.ជ.បប្រកាសនូវលទ្ធផលជាផ្លូវការ គណបក្សណាឈ្នះ តែងតែមានការអបអរសាទរ ។ ប៉ុន្តែពេលនេះរដ្ឋាភិបាលរាំង អត់ចេញសារបែបនេះទេ*" ។

ចំពោះលោក*កឹម សុខា* វិញ បានមានប្រសាសន៍ថា "*យើងមកតវ៉ានៅអន្តរជាតិនេះ យើងមានភស្តុតាងច្បាស់ឱ្យគេ ក្នុងនាមយើងតំណាងឱ្យប្រជាពលរដ្ឋមួយក្រុម ដើម្បីឱ្យគេដឹងថាការបោះឆ្នោតនេះ ពិតជាមិនត្រឹមត្រូវ មិនអាចទទួលយកបាន*" ។

នៅពេលដែលគេសួរថា តើលោកប្រធានគណបក្សប្រឆាំងមកទ្វីបអឺរ៉ុបនេះដើម្បីគ្រាន់តែជាបង្គ្រប់កិច្ច ឬក៏មានការគាំទ្រពីប្រទេសណាមួយនោះ ? លោក*សម រង្ស៊ី* បានមានប្រសាសន៍ថា "*មិនមែនបង្គ្រប់កិច្ចទេ គឺជាការបង្ហាញឱ្យធ្វើការផ្លាស់ប្តូរគំនិតរបស់គេនៅពេលដែលគេមើលមិនទាន់គ្រប់ជ្រុងជ្រោយ...*" ។ លោក*សម រង្ស៊ី* បានបន្តថាលោកនិងលោក*កឹម សុខា* នឹងជួបតំណាង រដ្ឋាភិបាល និងសមាជិកបារាំងហើយក៏ជួបជាមួយ អ្នកតំណាងរាស្ត្រសហភាពអឺរ៉ុប និងសមាជិកព្រមទាំងថ្នាក់ដឹកនាំ គណៈកម្មការអឺរ៉ុបផងដែរ ។

ព័ត៌មាន ដាច់ដោយឡែកមួយទៀតនៅទីក្រុងភ្នំពេញ គឺអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី ទាំង២៦រូប បានសរសេរលិខិតទូលថ្វាយព្រះមហាក្សត្រព្រះបរមនាថ*នរោត្តមសីហមុនី* ជាផ្លូវការហើយ កាលពីម្សិលមិញ បញ្ជាក់អំពីការមិនចូលរួមប្រជុំសភានៅថ្ងៃទី២៤ ខែកញ្ញា ២០០៨ ។

លិខិត របស់ក្រុមសមាជិកសភាគណបក្សសម រង្ស៊ី នេះគឺជាការឆ្លើយតប ព្រះរាជសារកោះហៅរបស់ព្រះមហាក្សត្រអោយអ្នកតំណាងរាស្ត្រ ទាំង១២៣រូបចូលរួមប្រជុំថ្ងៃដំបូងកាលពីថ្ងៃទី៨ កញ្ញា ២០០៨។

អ្នកច្បាប់ម្នាក់ បាននិយាយថា មហិច្ឆតារបស់គណបក្សប្រជាជនលោក*ហ៊ុន សែន* នឹងបង្ខំឱ្យព្រះមហាក្សត្រ ធ្វើជាព្រះរាជអធិបតីភាព នៅថ្ងៃប្រជុំដំបូង ខុសច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា៧៦ ដែលតម្រូវឱ្យមានសមាជិកសភាចូលរួមប្រជុំនៅលើកដំបូងយ៉ាងតិចចំនួន១២០រូប នៃអ្នកតំណាងរាស្ត្រចំនួន១២៣រូប ៕

**តមកពីទំព័រ១ ខ**

ឱ្យជួយអន្តរាគមន៍ដើម្បីយកដីទំហំ១១០ហិកតាមកទុកជាសម្បត្តិរួមវិញ។

ប្រការដែលប្រជាសហគមន៍ដែលមានគ្នា២៥០គ្រួសារទាមទារដល់លោក *ហ៊ុន សែន* និងភរិយាឱ្យជួយអន្តរាគមន៍រំលងសមត្ថកិច្ចចៅហ្វាយក្រុងព្រះសីហនុយ៉ាងដូច្នេះ បន្ទាប់ពីប្រជាសហគមន៍ដឹងថាក្រុមហ៊ុនហេងប៊ុនណាត ខូ អិល ធីឌី បានប្រើប្រាស់អំណាច ស.ជ.ណ រំលោភយកដីស្រែចំការ និងដីសហគមន៍ពួកគាត់ កាលពីពេលថ្មីៗនេះ។

តំណាងសហគមន៍បត់គគីរបានបង្ហើបឱ្យដឹងថា ក្រុមហ៊ុនហេង ប៊ុនណាត នេះបានរត់ការស្នើសុំ ស.ជ.ណ ពីរដ្ឋាភិបាលក្រោមរូបភាពវិនិយោគ និងអភិរក្សលើផ្ទៃដី៩៦៣ហិកតាសម្រាប់វិស័យទេសចរណ៍ធម្មជាតិស្ថិតក្នុងសង្កាត់បឹងតាព្រហ្ម និងសង្កាត់អូរឧកញ៉ាហេង។

ប៉ុន្តែការវិនិយោគរបស់ក្រុមហ៊ុនហេង ប៊ុនណាតហ្នឹងបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើស្រែចំការ និងដីសហគមន៍របស់ប្រជាពលរដ្ឋក្នុងសង្កាត់ទាំងពីរនេះដោយសារតែការចុះវាស់វែង និងគូរប្លង់រំលោភយកស្រែចំការ និងដីសហគមន៍តែម្តង។

ដោយមើលឃើញថា ក្រុមហ៊ុនហេងប៊ុនណាត ខូ អិលធីឌីយកអំណាច ស.ជ.ណ មករំលោភបំពានលើស្រែចំការនិងដីរបស់សហគមន៍យ៉ាងដូច្នេះ ទើបប្រជាពលរដ្ឋចំនួន២៥០គ្រួសារតំណាងដោយឈ្មោះ*រស់ ហាក់, អួង ខន* និង *ស៊ីវ ជន* បានរៀបចំជាលិខិតតវ៉ាមួយទៅមហាតេជោ *ហ៊ុន សែន* ។

ចម្លើយជាវិជ្ជមានរបស់នាយខុទ្ទកាល័យមហាតេជោ *ហ៊ុន សែន* កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨គឺលោក *ហូ សិទ្ធី* បានចេញដីកាបញ្ជូនលេខ ២២៦ ខន/០៨ ចុះថ្ងៃទី៣ ខែកញ្ញា ឱ្យចៅហ្វាយក្រុងព្រះសីហនុពិនិត្យមើលករណីនេះ។ ប៉ុន្តែថៅកែក្រុមហ៊ុនហេងប៊ុនណាត ខូ អិល ធីឌី ត្រូវជាកូនប្រសាររបស់លោក *ស្បោង សារ៉ាត* ទៅហើយ ទើបពុំមានការត្រួតពិនិត្យអ្វីសោះរហូតមកដល់ថ្ងៃនេះ។

យោងតាមរបាយការណ៍ស្តីពីដីព្រៃសហគមន៍ទំហំ១១០ហិកតានៅភូមិបត់គគីរ របស់លោក *រស់ ហាក់* ប្រធានគណៈកម្មការសហគមន៍នេសាទឧទ្យានជាតិព្រះសីហនុរាម, លោក *អួង ខន* ប្រធានសហគមន៍ភូមិបត់គគីរ និងលោក *ស៊ីវ ជន* ប្រធានសហគមន៍ភូមិអូរឧកញ៉ាហេងដាក់ជូនចៅហ្វាយក្រុងព្រះសីហនុកាលពីថ្ងៃទី៣ ខែកញ្ញាកន្លងទៅបានបញ្ជាក់ច្បាស់ថា "*ឧទ្យានជាតិព្រះសីហនុរាម និងការកំណត់តំបន់ការពារធម្មជាតិត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣* "។

ម្យ៉ាងទៀតសហគមន៍នេះក៏បានបង្កើតឡើងក្រោយពេលដែលឧទ្យានជាតិព្រះសីហនុរាមលេចចេញជារូបរាងហើយៗ សហគមន៍នេះទៀតសោតក៏មានការទទួលស្គាល់ពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងមានការជួយឧបត្ថម្ភពីអង្គការដានីដា, មន្ទីរបរិស្ថាន, ស្នាក់ការឧទ្យានជាតិព្រះសីហនុរាម ដោយមានសមាជិកចូលរួមពីភូមិបត់គគីរចំនួន១៥០គ្រួសារ និងភូមិអូរឧកញ៉ាហេងចំនួន១០០គ្រួសារក្នុងគោលបំណងជួយការពារព្រៃធម្មជាតិដែលស្ថិតនៅក្បែរៗផ្ទះអ្នកភូមិ ប៉ុន្តែសហគមន៍នេះពុំទាន់បានប្រកាសជាផ្លូវការឡើយ។

របាយការណ៍បានបន្តទៀតថា "*ក្រោយពីការរៀបចំសមាជិកសហគមន៍រួចហើយ ក៏មានកិច្ចប្រជុំវិសាមញ្ញមួយនៅក្នុងសហគមន៍ ដែលកិច្ចប្រជុំនោះក៏មានវត្តមានលោក ម៉ុក ម៉ារ៉េត* រដ្ឋមន្ត្រីក្រសួងបរិស្ថានជាអធិបតីផងដែរនិងបានសម្រេចប្រគល់ដី១១០ហិកតាជាប់បណ្តោយផ្លូវជាតិលេខ៤ស្ថិតក្នុងភូមិបត់គគីរ ឱ្យមកសហគមន៍ការពាររក្សាព្រៃឈើទុកជាដីសហគមន៍រហូតដល់ថ្ងៃទី៩ ខែតុលាឆ្នាំ១៩៩៨ មន្ត្រីឧទ្យានជាតិទាំងអស់តំណាងក្រសួងបរិស្ថាន, គណៈកម្មការសង្កាត់, ប្រធានសហគមន៍ និងក្រុមការងារសហគមន៍បានចុះបោះបង្គោលដាក់ស្លាកផ្ទាំងថ្មនៅគ្រប់ជ្រុងនៃព្រំដី។

ជាងនេះទៀតនៅមានការវាស់វែងដីកំណត់ព្រំឱ្យសហគមន៍ និងប្រគល់សេចក្តីប្រកាសទទួលស្គាល់ការបង្កើតសហគមន៍ព្រៃឈើ និងសហគមន៍ជលផលក្នុងតំបន់អភិវឌ្ឍន៍សហគមន៍ នឹងតំបន់ទ្រនាប់នៃឧទ្យានជាតិព្រះសីហនុរាមថែមទៀតផង។

ប៉ុន្តែប្រការដែលធ្វើឱ្យប្រជាសហគមន៍មានការភ្ញាក់ផ្អើលនោះ គឺមិនដឹងថា ក្រុមហ៊ុនហេង ប៊ុនណាត ខូ អិល ធីឌី ចេះរត់ការតាមរបៀបលោតផ្លោះហោះផ្លោង ឬយ៉ាងណានោះទេ ស្រាប់តែគេកាន់ ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ៧៨៣ ស.ជ.ណ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ និងចុះហត្ថលេខាដោយលោក*ប្រាក់ សុខុន* រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីមកវាតទីយកអស់ស្រែចំការ និងដីសហគមន៍ម៉ដ្ឋដូចអាចម៍ទីទុយតែម្តង។

គេថាករណីដីសហគមន៍ទំហំ១១០ហិកតានេះបើឱ្យប្រជាពលរដ្ឋទៅពឹងពាក់លោក *ស្បោង សារ៉ាត* ជាចៅហ្វាយក្រុងទើបនឹងឡើងថ្មីវិញ គឺដូចជួយឱ្យក្រុមហ៊ុន ហេង ប៊ុនណាត ខូ អិលធីឌីក្លាយជាខ្លាដុះស្លាបទៅវិញទេ ព្រោះថៅកែក្រុមហ៊ុននេះត្រូវជាកូនប្រសាររបស់លោក *ស្បោង សារ៉ាត* ស្មោះ!។

ឥឡូវនេះប្រជាសហគមន៍បានធ្វើការអំពាវនាវយ៉ាងទទូចទៅមហាតេជោ *ហ៊ុន សែន* ដើម្បីជួយអន្តរាគមន៍ក្នុងរឿងនេះផង។ ប៉ុន្តែមានមជ្ឈដ្ឋានខ្លះបាននិយាយដោយត្រង់ៗថា មានតែលោក *ម៉ុក ម៉ារ៉េត* រដ្ឋមន្ត្រីក្រសួងបរិស្ថានទេទើបអាចដោះស្រាយបញ្ហានេះបាន បើពុំដូច្នោះទេ គឺដីសហគមន៍ទំហំ១១០ហិកតានេះមិនអាចគេចផុតពីមហិច្ឆតាក្រុមគ្រួសារលោក *ស្បោង សារ៉ាត* បានឡើយ។

តំណាងហសគមន៍ភូមិបត់គគីរមួយរូបបានអះអាងថា ប្រជាសហគមន៍ទាំង២៥០គ្រួសារនឹងមិនចុះញ៉មថៅកែក្រុមហ៊ុនហេងប៊ុនណាត ខូ អិល ធីឌីជាដាច់ខាត។

ឃើញទេគ្រាន់តែគណបក្សប្រជាជនឈ្នះឆ្នោតដោយការលួចបន្លំបានច្រើនអាសនៈភ្លាម បញ្ហារំលោភដីធ្លីរបស់រដ្ឋ និងរបស់ប្រជាពលរដ្ឋបានកើតឡើងយ៉ាងកោលាហលភ្លាមៗដែរ ដែលធ្វើឱ្យប្រជាពលរដ្ឋខ្មែរក្តៅក្រហាយនឹងបរិវាររបស់មហាតេជោ *ហ៊ុន សែន* សម្បើមណាស់៕

**តមកពីទំព័រ៤ ន**

*តាមទីផ្សារអន្តរជាតិនេះ* "។

លោក*សុន ឆ័យ* បានថ្លែងថា គណបក្សសម រង្ស៊ី សំដែងនូវការព្រួយបារម្ភ យ៉ាងខ្លាំងអំពីអនាគត បើសិនជារដ្ឋសភាខ្មែរ នៅតែបន្តធ្វើការងារតាមរបៀបប្រថាប់ត្រាឱ្យរដ្ឋាភិបាលហើយបក្ស រដ្ឋតែមួយដូចការគ្រប់គ្រងក្នុងទសវត្សរ៍១៩៨០នោះ, បើទោះបីជាតម្លៃប្រេងនៅលើទីផ្សារពិភពលោក ចុះមកនៅត្រឹម៤០ដុល្លារ នៅក្នុងមួយបារ៉េល ក៏គ្មាននរណាអាចជួយប្រជាពលរដ្ឋបានដែរ ។

លោក*សុន ឆ័យ* បានបន្តថា ដោយសារតែមន្ត្រីជាន់ខ្ពស់ខ្មែរខ្លះ មានភាគហ៊ុនជាមួយក្រុមហ៊ុនប្រេងឥន្ធនៈនេះហើយទើបទីផ្សារប្រេង នៅកម្ពុជាតម្លៃថ្លៃខ្ពស់តាមចិត្តហើយមិនព្រមបញ្ចុះតម្លៃ ឱ្យស្របទៅតាមទីផ្សារអន្តរជាតិ ។

ទោះយ៉ាងណា គណបក្សប្រជាជន គ្មានគោលនយោបាយក្នុងការបញ្ចុះតម្លៃប្រេង នៅលើទីផ្សារអោយស្របទៅតាមទីផ្សារអន្តរជាតិទេ ។ ដូច្នេះហើយ បានជាគណបក្សប្រជាជន ដែលលួចបន្លំសន្លឹកឆ្នោតបាន៩០កៅអី កាលពីការបោះឆ្នោតថ្ងៃទី២៧ កក្កដា ២០០៨ នោះមិនខ្វល់នឹងថ្លៃប្រេងសាំងធ្លាក់ចុះ នៅលើទីផ្សារអន្តរជាតិដូចសព្វថ្ងៃឡើយ ៕

**តមកពីទំព័រ១ ឃ**

មួយវិទ្យុបារាំងអន្តរជាតិកាលពីយប់ថ្ងៃទី១០ ខែកញ្ញាកន្លងទៅហើយនៅថ្ងៃនេះលោកទាំងពីរកំពុងស្ថិតនៅទីក្រុងប្រ៊ុចសែលជារដ្ឋធានីនៃប្រទេសប៊ែលហ្ស៊ិក និងជារដ្ឋធានីនៃសហភាពអឺរ៉ុប ដើម្បីបន្តការតវ៉ា តាមរយៈការគ្រោងជួបជាមួយតំណាងរាស្ត្រ និងតំណាងនៃរដ្ឋាភិបាលប្រទេសនានា។

ជាការឆ្លើយតបចំពោះសំណួររបស់វិទ្យុបារាំងអន្តរជាតិថា ថ្មីៗនេះព្រះមហាក្សត្រខ្មែរទ្រង់ត្រាស់បង្គាប់ឱ្យសមាជិកសភា១២៣រូបចូលរួមប្រជុំសភាថ្ងៃដំបូង គ្រោងធ្វើនៅថ្ងៃទី២៤ ខែកញ្ញាខាងមុខនេះ លោក *សម រង្ស៊ី* បានមានប្រសាសន៍ថា លោករួមជាមួយតំណាងរាស្ត្រជាប់ឆ្នោតថ្មីគណបក្សលោក និងគណបក្សសិទ្ធិមនុស្សនឹងមិនចូលរួមការប្រជុំនោះទេ។

លោក *សម រង្ស៊ី* បានថ្លែងយ៉ាងនេះថា "*គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សមានជំហរដូចគ្នា គឺមិនចូលរួមប្រជុំនោះទេ។ យើងនឹងមិនចូលរួមប្រជុំទេ បើចូលមានន័យថា យើងទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ហើយយើងទៅអង្គុយចាំប្រថាប់ត្រា* "។លោកបានបញ្ជាក់បន្ថែមថាយ៉ាងណាក៏គណបក្សសមរង្ស៊ីជាមួយដៃគូនឹងចូលទៅក្នុងសភាវាងពីរទៅបីថ្ងៃនៅក្រោយការប្រជុំសភាលើកដំបូងនៃគណបក្សប្រជាជន។

ស្របជាមួយគ្នានឹងការថ្លែងជំហររបស់លោក*សម រង្ស៊ី* នោះ លោក *កឹមសុខា*មេដឹកនាំនៃគណបក្សសិទ្ធិមនុស្ស ក៏បានប្រកាសអំពីជំហរដូចគ្នា។

លោក*កឹមសុខា*បាននិយាយយ៉ាងនេះថា យើងមានជំហរដូចគ្នានឹងគណបក្សសមរង្ស៊ី។ សមាជិកសភាយើង៣នាក់នឹងមិនចូលប្រជុំសភានៅថ្ងៃទី២៤ កញ្ញា ជាថ្ងៃដំបូងនោះទេ។

ចំពោះការឆ្លើយបញ្ជាក់យ៉ាងច្បាស់នូវជំហរថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សទាំងពីរ ដែលកំពុងស្វែងរកការគាំទ្របុព្វហេតុប្រឆាំងនឹងការបោះឆ្នោតនៅកម្ពុជា លួចបន្លំដោយគណបក្សប្រជាជននោះ។ វិទ្យុបារាំងអន្តរជាតិបានលើកជាសំណួរទៀតថា ប្រសិនបើមិនចូលប្រជុំនោះ ដោយសារថាការប្រជុំនោះជាការត្រាស់បង្គាប់របស់ព្រះមហាក្សត្រ ដូច្នេះនឹងមានន័យថា គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស មិនមានការគោរពស្តេចទេ ឬអ្វី ?

លោក*សមរង្ស៊ី*បានបញ្ជាក់យ៉ាងនេះថា "*យើងមិនមែនមិនគោរពស្តេចយ៉ាងហ្នឹងទេ។ ព្រះមហាក្សត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាពុំមានអំណាចទេ។អ្វីដែលគណបក្សប្រជាជនស្នើឡើង ព្រះមហាក្សត្រតែងតែធ្វើតាម* "។

ហើយដើម្បីជាការបញ្ជាក់ឱ្យច្បាស់នោះ លោកបានមានប្រសាសន៍ចំៗយ៉ាងនេះថា "*ដូចករណីលើកលែងទោសថ្វាយសម្តេចក្រុមព្រះ នរោត្តម រណប្ញទ្ធិ ក៏ត្រូវរង់ចាំភ្លើងខៀវពីគណបក្សប្រជាជនដែរ។រឿងនេះមិនមែនជាការគោរពឬមិនគោរពស្តេចនោះទេ តាមសតិសម្បជញ្ញៈយើង។ សម្បជញ្ញៈយើងមិនអនុញ្ញាតឱ្យយើងចូលរួមប្រជុំសភាដែលជាតំណាងខ្មោច តំណាងចោរ តំណាងយួននោះឡើយ* "។

លោកបានពិពណ៌នាយ៉ាងក្បោះក្បាយថា តំណាងរាស្ត្រគណបក្សប្រជាជនមួយចំនួនគឺជាតំណាងចោរ ដោយសារគេបានកៅអីសភាពីការលួចបន្លំសន្លឹកឆ្នោត ហើយក៏ជាតំណាងខ្មោចដែលមានគណបក្សប្រជាជនប្រើប្រាស់ គ.ជ.ប ឱ្យយកឈ្មោះមនុស្សដែលស្លាប់ទៅហើយមកចុះជាឈ្មោះសម្រាប់ឱ្យគេបោះឆ្នោតទាំងលោកបានហៅទៀតថា សមាជិកសភាគណបក្សប្រជាជនក៏ជាតំណាងយួននោះដែរ ពីព្រោះពួកគេបានបង្ខំយួនឱ្យចូលបោះឆ្នោតឱ្យគណបក្សប្រជាជន។

ហើយអំពីការដែលសមាជិកសភានៃគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សរួមគ្នាទាំង២៩រូបបានប្រកាន់ជំហររួម ដោយធ្វើការស្នើសុំតាមរយៈលិខិតដាច់ដោយឡែកពីគ្នាទៅព្រះមហាក្សត្ររកការប្រោសប្រទានធ្វើពិធីសច្ចាប្រណិធានសម្រាប់គណបក្សទាំងពីរដោយឡែកពីគណបក្សប្រជាជននោះ វិទ្យុបារាំងអន្តរជាតិក៏បានលើកជាសំណួរដែរថា "*តើព្រះមហាក្សត្រយល់ព្រមឬទេដែលសមាជិកសភាគណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សសុំស្បថដោយឡែកពីគណបក្សប្រជាជននោះ* "?

ចំពោះសំណួរនេះលោក *កឹម សុខា* បានផ្តល់ចម្លើយថា យើងបានធ្វើលិខិតថ្វាយទៅព្រះមហាក្សត្រ។ប៉ុន្តែយើងអត់ទាន់បានទទួលចម្លើយទេ។យើងរង់ចាំចម្លើយរបស់លោក។លោកត្រាស់បង្គាប់ឱ្យមានការចូលប្រជុំសភា រឿងនេះមិនពាក់ព័ន្ធនឹងការស្នើសុំរបស់យើងទេ។ហើយនេះជាហេតុដែលយើងបានសម្រេចចិត្តថា យើងនឹងមិនទៅចូលរួមប្រជុំសភានៅថ្ងៃទី២៤ ខែកញ្ញានោះទេ ដោយត្រូវរង់ចាំចម្លើយពីព្រះមហាក្សត្រ។

ចំពោះមុខការបញ្ជាក់យ៉ាងច្បាស់នូវជំហរសមាជិកសភាគណបក្សទាំងពីរមិនចូលប្រជុំសភាថ្ងៃដំបូងនេះ វិទ្យុបារាំងបានលើកអំពីករណីដែលប្រព័ន្ធផ្សព្វផ្សាយនេះហៅថា សភាអឺរ៉ុប ប្រទេសជប៉ុន សហរដ្ឋអាមេរិកបានវាយតម្លៃថាការបោះឆ្នោតឆ្នាំ២០០៨នេះល្អជាងការបោះឆ្នោតលើកមុនៗ ថ្វីបើមានការទទួលស្គាល់ថា មិនឆ្លើយតបទៅនឹងស្តង់ដារអន្តរជាតិក៏ដោយនោះ។ តាមការយល់របស់វិទ្យុនេះថា នេះមានន័យថាជាការទទួលស្គាល់ជាប្រយោលលទ្ធផលនៃការបោះឆ្នោតថ្ងៃទី២៧ ខែកក្កដានៅកម្ពុជានោះ ហើយថា លោកប្រធាននៃគណបក្សទាំងពីរចេញមកក្រៅរកការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងប្រទេសនានាគ្រាន់តែជាការបង្គ្រប់កិច្ច ឬមួយក៏ដឹងច្បាស់ថាមានអ្នកគាំទ្រដែរនោះ លោក*សម រង្ស៊ី*បានផ្តល់ចម្លើយបំភ្លឺយ៉ាងច្បាស់លាស់។

លោកប្រធាន *សម រង្ស៊ី* បានមានប្រសាសន៍ជាចម្លើយយ៉ាងនេះថាអ្វីដែលលោក*ស្បង់ ហូរតាន់* បកស្រាយនេះ គឺជាប្រធានបទផ្ទាល់ខ្លួន។សហភាពអឺរ៉ុបបានចេញសេចក្តីថ្លែងការណ៍មិនមែនថាគេគាំទ្រលទ្ធផលនៃការបោះឆ្នោតនេះទេ។

ចំពោះចម្លើយនេះវិទ្យុបារាំងអន្តរជាតិបានលើកជាសំណួរបន្ថែមថា ការបោះឆ្នោតនេះមានលក្ខណៈល្អជាងលើកមុនៗនោះ។ដើម្បីបញ្ចប់ចម្ងល់របស់វិទ្យុបារាំងអន្តរជាតិ លោក *សម រង្ស៊ី* ក៏បានលើកពន្យល់យ៉ាងក្បោះក្បាយថាមែនហើយការបោះឆ្នោតលើកនេះមានចំណុចល្អជាងមុនខ្លះ ក៏ប៉ុន្តែក៏មានចំណុចអាក្រក់ជាងមុនដែរហើយ អ្វីដែលអាក្រក់បំផុតជាងការបោះឆ្នោតមុនៗនោះគឺការលួចប្លន់សន្លឹកឆ្នោតយ៉ាងស្រស់ៗនោះ៕

**តមកពីទំព័រ២ គ**

ទួលប្រាសាទ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យជាដើម ត្រូវលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដកចេញពីតួនាទីភ្លាម ដោយសារតែគាត់ (ឃួន វណ្ណា) ស្រឡាញ់ជាតិ ស្រឡាញ់ទឹកដី និងស្រឡាញ់ប្រជាពលរដ្ឋ ដឹកនាំកម្លាំងប្រយុទ្ធខ្មែរ ប្រឆាំងនឹងចោរឈ្លានពានសៀម ដុតលំនៅឋាន និងចាប់ប្រជាពលរដ្ឋខ្មែរ នៅក្នុងតំបន់នោះ ។

លោក*ឃួន វណ្ណា*ពិការជើងទាំងពីរប៉ុន្តែទឹកចិត្តស្នេហាជាតិរបស់គាត់នោះ មិនពិការដូចមេដឹកនាំខ្មែរដទៃទៀតទេ ជាពិសេសមេទ័ពខ្មែរសព្វថ្ងៃ។ទឹកចិត្តស្នេហាជាតិ របស់លោក *ឃួន វណ្ណា* បានធ្វើឱ្យពួកចោរសៀម លែងព្រហើន ខ្លបខ្លាច និងមិនហ៊ានរំលោភបំពានចូលដីខ្មែរក្នុងតំបន់ដែលលោកគ្រប់គ្រងនោះឡើយ ។ ទឹកចិត្តដ៏ស្នេហាជាតិ របស់លោក*ឃួន វណ្ណា* នេះ បានធ្វើឱ្យសម្តេចឪព្រះ*នរោត្តម រណប្ញទ្ធិ* សព្វព្រះទ័យ ហើយប្រទានមេដាយជាការលើកទឹកចិត្ត ក្នុងការការពារបូរណភាពទឹកដី ។

ប៉ុន្តែស្ថានភាពព្រំដែន នៅឃុំប៉ោយប៉ែត ហាក់ដូចជាស្ងប់ស្ងាត់ហើយ នៅរយៈពេលចុងក្រោយនេះ ពិសេសបន្ទាប់ពីលោក*ឃួន វណ្ណា* ដឹកនាំកម្លាំងប្រឆាំងសៀម ថែមទាំងមានការផ្ទុះអាវុធមួយប្រាវផងនោះ ទើបធ្វើឱ្យទាហានសៀម រាគអាចម៍ លែងហ៊ានមើលងាយខ្មែរ និងចូលក្នុងដីខ្មែរទៀត ។ ឥឡូវទាហានសៀម បានឈ្លានពានបូរណភាពទឹកដីខ្មែរ នៅក្បែរប្រាសាទព្រះវិហារ តំបន់ជប់គគីរ ប្រាសាទតាមាន់ធំនិងពិសេសនោះ គឺទាហានសៀមជាង១០០នាក់ បានឈ្លានពានយ៉ាងកំរោល ចូលក្នុងប្រាសាទតាក្របីរបស់ខ្មែរ ។ ប៉ុន្តែពួកសមាជិកគណៈរដ្ឋមន្ត្រី ដែលគ្រោងនឹងទទួលតំណែងថ្មី នៅចុងខែនេះ មិនខ្វល់នឹងពួកចោរសៀមឈ្លានពានទេ,ហើយពួកគេ ត្រៀមជប់លៀងឱ្យក្រើកក្រុងភ្នំពេញ បន្ទាប់ពីរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់ បង្កើតជាផ្លូវការនាចុងខែនេះ ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

-មានទទួលទិញក្នុងតម្លៃសមរម្យ

-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្តជនបទ**

**មានទទួលបញ្ចាំង**
**ខ្សែភាពយន្តខ្នាតធំ**
**ក្នុងពិធីផ្សេងៗ**
**មានពន្លឺច្បាស់**
**ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com

ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ ម**

ការទូលសុំបែបនេះបន្ទាប់ពីសហភាពសហជីពកម្ពុជាមើលឃើញថា អស់រយៈពេលជិត២ខែទៅហើយដែលទាហានសៀមនៅតែបន្តវត្តមានរបស់ខ្លួនយ៉ាងគឃ្លើនលើទឹកដីនៃប្រទេសកម្ពុជា ពិសេសគឺការចរចារបស់រដ្ឋាភិបាលកន្លងមកពុំទទួលបាននូវលទ្ធផលអ្វីគួរជាទីសង្ឃឹមឡើយ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី១១ ខែកញ្ញាម្សិលមិញនេះ លោក *រ៉ុង ឈុន* ប្រធានសហភាពសហជីពកម្ពុជាបានធ្វើជាលិខិតមួយច្បាប់ផ្ញើថ្វាយព្រះករុណាព្រះមហាក្សត្រដើម្បីឱ្យព្រះអង្គមានព្រះរាជតម្រិះចំពោះអំពើឈ្លានពានដ៏កម្រោលរបស់ទាហានសៀម។

លិខិតរបស់លោក*រ៉ុង ឈុន*នោះបានទូលថ្វាយព្រះមហាក្សត្រយ៉ាងក្បោះក្បាយថា "*អស់រយៈពេលជិត២ខែហើយដែលកងទ័ពសៀមមិនព្រមបោះបង់នូវមហិច្ឆតាចង់បានទឹកដីខ្មែរដោយមិនព្រមដកទ័ពថយចេញពីទឹកដីកម្ពុជាសោះបន្ទាប់ពីកម្លាំងកងទ័ពសៀមទាំងនោះបានចូលមកឈ្លានពានទឹកដីខ្មែរចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨នៅតាមបណ្តោយព្រំដែនកម្ពុជា-សៀម ជាពិសេសនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ (វត្តកែវសិក្ខាគិរីស្វារៈ) និងភូមិសាស្ត្រខេត្តឧត្តរមានជ័យ (ប្រាសាទតាមាន់ធំ និងតាមាន់តូច)*"។

ជាមួយគ្នានេះដែរ លិខិតលោក*រ៉ុងឈុន*ប្រធានសហភាពសហជីពកម្ពុជាបានបញ្ជាក់ច្បាស់ថា រដ្ឋាភិបាលកម្ពុជាបានផ្តល់ឱកាសបើកការចរចាតាមផ្លូវការទូតរវាងប្រទេសទាំងពីរក្នុងន័យរក្សាចំណងមិត្តភាពសន្តិភាពជាប្រទេសជិតខាងគ្នាម្តងជាពីរដងរួចហើយក៏ដោយ ក៏រដ្ឋាភិបាលសៀមមិនបានបញ្ជាឱ្យកងទ័ពរបស់ខ្លួនដកចេញពីទឹកដីខ្មែរនោះទេ។

លោក *រ៉ុង ឈុន* បានសង្កត់ធ្ងន់ថា "*រដ្ឋាភិបាលសៀមមិនត្រឹមតែមិនដកកងទ័ពប៉ុណ្ណោះទេ គឺថែមទាំងឈ្លានពានជាបន្តបន្ទាប់ និងប្រមាថធ្វើបាបនិងបាញ់សម្លាប់ប្រជាពលរដ្ឋខ្មែរដែលរស់នៅតាមព្រំដែនទៀតផង*"។

លិខិតបានទូលថ្វាយព្រះមហាក្សត្រខ្មែរទៀតថា "*បញ្ហាកងទ័ពសៀមឈ្លានពានទឹកដីខ្មែរកាន់តែធ្ងន់ធ្ងរទៅៗពីមួយថ្ងៃ ទៅមួយថ្ងៃ។ ហើយក្នុងនាមជាប្រជាពលរដ្ឋខ្មែរមានការកង្វល់យ៉ាងខ្លាំងចំពោះថ្នាក់ដឹកនាំរដ្ឋាភិបាលខ្មែរសព្វថ្ងៃដែលមានជំហរមិនច្បាស់លាស់ធ្វើឱ្យពេលវេលាចេះតែអូសបន្លាយដែលអាចធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី*"។

លោក *រ៉ុង ឈុន* បានបន្តទៀតថា ដើម្បីធានាឯករាជ្យជាតិ អធិបតេយ្យជាតិ និងបូរណភាពទឹកដីខ្មែរ "*ទូលព្រះបង្គំសូមព្រះអង្គប្រើព្រះរាជសិទ្ធិរបស់ព្រះអង្គដោយយោងតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាក្នុងជំពូក២ ត្រង់មាត្រា៨ដែលបានចែងថាព្រះមហាក្សត្រទ្រង់ជានិមិត្តរូបនៃការឯកភាពជាតិ និងនិរន្តរភាពជាតិ។ ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា។ ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ*"។

យោងតាមរដ្ឋធម្មនុញ្ញបែបនេះហើយ ទើបលោក *រ៉ុង ឈុន* ប្រធានសហភាពសហជីពកម្ពុជាស្នើសុំឱ្យព្រះមហាក្សត្រប្រើប្រាស់នូវព្រះរាជសិទ្ធិរបស់ព្រះអង្គក្នុងការដោះស្រាយបញ្ហាកងទ័ពសៀមឈ្លានពានដែលចង់បានទឹកដីខ្មែរយ៉ាងគឃ្លើនបំផុត។

មុននេះបន្តិចសហភាពសហជីពកម្ពុជាបានស្នើទៅសាលាក្រុងភ្នំពេញដើម្បីដឹកនាំកម្លាំង៣០០នាក់ធ្វើបាតុកម្មប្រឆាំងនឹងការឈ្លានពានរបស់ទាហានសៀម។ ប៉ុន្តែគ្រាន់តែដល់ថ្ងៃកំណត់ក៏ត្រូវកម្លាំងរដ្ឋាភិបាលបង្ក្រាបដល់ទីកន្លែងតែម្តង។

កន្លងមកការដកពាក្យបណ្តឹងពីក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិចំពោះករណីសៀមឈ្លានពានប្រទេសកម្ពុជានោះ ត្រូវបានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាចេញសេចក្តីថ្លែងការណ៍ជំទាស់យ៉ាងខ្លាំងក្លាបំផុត។

មិនតែប៉ុណ្ណោះក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាដដែលនេះនៅបានថ្កោលទោសចំពោះកិច្ចចរចារបស់រដ្ឋាភិបាលក្រុងភ្នំពេញជាមួយភាគីសៀមមានលក្ខណៈឱនលំទោនជ្រុលពេក ដែលជាសញ្ញាមួយបង្ហាញឱ្យសាធារណៈមតិជាតិ អន្តរជាតិមើលឃើញថាកម្ពុជាកំពុងចាញ់ប្រៀបចោរសៀមហើយ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាបានលាតត្រដាងតាមសេចក្តីថ្លែងការណ៍របស់ខ្លួនយ៉ាងដូច្នេះថា "*ករណីប្រាសាទព្រះវិហារគឺកម្ពុជាបានឈ្នះក្តីនៅតុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេតាំងពីឆ្នាំ១៩៦២មកម្ល៉េះ។ដូច្នេះកម្ពុជាមិនចាំបាច់ធ្វើការចរចាជាមួយសៀមឡើយ។ហើយចាំបាច់ត្រូវតែប្តឹងទៅតុលាការអន្តរជាតិជាបន្ទាន់ដើម្បីឱ្យស្របតាមសន្ធិសញ្ញាឆ្នាំ១៩៣៧*"។

ជាងនេះទៀត ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាបានជម្រុញឱ្យរដ្ឋាភិបាលក្រុងភ្នំពេញអនុវត្តន៍តាមគោលការណ៍មួយចំនួនដូចខាងក្រោមនេះ :

១-មិនត្រូវដកពាក្យបណ្តឹងរបស់ខ្លួនពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឡើយ។

២-ត្រូវប្តឹងតុលាការអន្តរជាតិដោយឈរលើមូលដ្ឋានសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤ ឆ្នាំ១៩០៧ និងសាលក្រមតុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេឆ្នាំ១៩៦២ ព្រមទាំងផែនទីភ្ជាប់នឹងសាលក្រមនេះ។

៣-ត្រូវដាក់បណ្តឹងទៅបណ្តាប្រទេសជាម្ចាស់ហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១។

៤-ត្រូវផ្សព្វផ្សាយជាសាធារណៈនូវរាល់ឯកសារនិងលទ្ធផលនៃការចរចា។

ប៉ុន្តែវាជាប្រការមួយគួរឱ្យសោកស្តាយណាស់ ព្រោះរដ្ឋាភិបាលខ្មែរមិនខ្វល់នឹងការដាស់តឿនក្រើនរំលឹកបែបនេះឡើយ ហើយនៅតែបន្តប្រព្រឹត្តទៅតាមគំនិតកំសាកខ្លាចបាត់បង់ផលប្រយោជន៍ របស់ខ្លួន រហូតបរាជ័យដល់សព្វថ្ងៃ។

គេមិនទាន់ដឹងឱ្យប្រាកដថា តើព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី*ព្រះមហាក្សត្រខ្មែរព្រះអង្គមានព្រះរាជតម្រិះយ៉ាងណានោះទេ។ តែប្រសិនបើព្រះអង្គហ៊ានប្រើប្រាស់នូវព្រះរាជសិទ្ធិរបស់ព្រះអង្គស្របតាមរដ្ឋធម្មនុញ្ញក្នុងការដោះស្រាយបញ្ហាកងទ័ពសៀមឈ្លានពានកម្ពុជាមែននោះគឺមានប្រជាពលរដ្ឋខ្មែរច្រើនណាស់នឹងដង្ហែតាម ព្រះរាជតម្រិះនិងព្រះរាជបេសកកម្មជាប្រវត្តិសាស្ត្ររបស់ព្រះអង្គដើម្បីទឹកដីស្ថិតស្ថេរគង់វង្សជាអមតៈ៕

**តមកពីទំព័រ១ ន**

ធ្វើឱ្យអង្គការ OPEX ដែលជាស្ថាប័នផលិតប្រេងឆៅ នៅលើពិភពលោក សំដែងការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។

តម្លៃទីផ្សារប្រេងឆៅ នៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស កាលពីថ្ងៃទី៩ កញ្ញា ២០០៨ គឺនៅសល់តែ៩៩,៣០ ដុល្លារប៉ុណ្ណោះ ។ ឯតម្លៃប្រេងឆៅនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិកវិញ បានចុះនៅត្រឹមតែ១០២ដុល្លារទេ ក្នុងមួយធុងប៉ុណ្ណោះ កាលពីថ្ងៃទី១០កញ្ញា ឯទីផ្សារនៅកម្ពុជាវិញ គឺខ្ពស់កប់ពពកដដែល ដែលការមិនបញ្ចុះតម្លៃ ឱ្យស្របទៅនឹងទីផ្សារពិភពលោកនេះ ត្រូវបានមន្ត្រីគណបក្សសមរង្ស៊ីថ្លែងថា ជាការជញ្ជក់ឈាម ប្រជាពលរដ្ឋ ពីសំណាក់អ្នកមានអំណាចគ្មានត្រាប្រណី ។

លោក*សុន ឆ័យ* សមាជិកសភាមណ្ឌលភ្នំពេញនិងជាអ្នកនាំពាក្យ គណបក្សសម រង្ស៊ី បានប្រាប់*ខ្មែរម្ចាស់ស្រុក* កាលពីព្រឹកម្សិលមិញថា"*យើងមានការព្រួយបារម្ភនិងមិនសប្បាយចិត្ត ចំពោះស្ថានភាព អំពីតម្លៃប្រេង ដូចបងប្អូនជនរួមជាតិយើងដូច្នោះដែរ ។ យើងបានឃើញថាតម្លៃប្រេងនៅកម្ពុជាដែលបានឡើងថ្លៃ រហូតដល់៥.៧០០រៀល ក្នុងមួយលីត្រនោះនៅពេលដែលតម្លៃប្រេងលើទីផ្សារអន្តរជាតិ ឡើងដល់១៤៨ដុល្លារក្នុងមួយធុង ។ តែឥឡូវនេះ តម្លៃប្រេងធ្លាក់មកនៅក្រោម ១០០ដុល្លារហើយ ក្នុងមួយធុង គឺបានន័យថាធ្លាក់តម្លៃមួយភាគបីហើយ* " ។

លោក*សុន ឆ័យ* បានថ្លែងថា បើតាមតម្លៃទីផ្សារសេរីគឺទីផ្សារប្រេង នៅប្រទេសកម្ពុជាត្រូវតែបញ្ចុះតម្លៃ អោយនៅយ៉ាងខ្ពស់បំផុត ៣.៨០០រៀលក្នុងមួយលីត្រ។ លោកបានបន្តថា រដ្ឋាភិបាលនិយាយគ្មានការពិតទេ ដែលកន្លងទៅមន្ត្រីរដ្ឋាភិបាលនិយាយថា មិនអាចទប់តម្លៃប្រេងឡើងថ្លៃបានទេ ពីព្រោះការឡើងនេះគឺឡើងតាមតម្លៃទីផ្សារអន្តរជាតិ ។ ប៉ុន្តែឥឡូវ ទីផ្សារអន្តរជាតិ បានចុះមួយភាគបីហើយ ហេតុអ្វីបានជាទីផ្សារនៅកម្ពុជា មិនព្រមចុះថ្លៃ ដែលនេះជាការកេងប្រវ័ញ្ច និងហុតឈាមប្រជាពលរដ្ឋខ្មែរ។ លោក*សុន ឆ័យ* បានមានប្រសាសន៍ថា ក្រុមហ៊ុនប្រេងនៅកម្ពុជា ដូចជាក្រុមហ៊ុនសូគីម៉ិចជាដើម គឺគេបានទិញប្រេងស្តុកទុកច្រើន ដែលគេទិញនោះ តាំងពីនៅតម្លៃថោកប៉ុន្តែគេតម្លើងថ្លៃភ្លាមឱ្យស្រប តាមទីផ្សារពិភពលោកដែរ, តែនៅពេលទីផ្សារពិភពលោកចុះថ្លៃមកវិញ គេមិនចុះទេ ដោយគេយកលេសថា គេទិញស្តុកទុកនោះ កាលពីនៅថ្លៃ ។

លោក*សុន ឆ័យ* បានរិះគន់រដ្ឋាភិបាលថាមិនបានពិនិត្យឱ្យបានត្រឹមត្រូវ ចំពោះការលក់ប្រេងនៅលើទីផ្សារសេរី ថាតើប្រេងចាស់ ឬប្រេងទើបតែនាំចូលថ្មី ដើម្បីកុំឱ្យឈ្មួញចេះតែតម្លើងតម្លៃប្រេង តាមតែចិត្តនោះ ។ លោកបានបន្តថា ការដែលរដ្ឋាភិបាលមិនធ្វើការត្រួតពិនិត្យ ឱ្យក្រុមហ៊ុនបញ្ចុះតម្លៃប្រេង ឱ្យស្របទៅតាមទីផ្សារអន្តរជាតិនេះ វាជាការបង្ហាញឱ្យឃើញ អំពីការគ្រប់គ្រងប្រទេសបែបអនាធិបតេយ្យដែលនាំឱ្យជួបការលំបាក ដល់ប្រជាពលរដ្ឋ ។

ចំពោះសំណួរ ដែលសួរថា តើគណបក្សសម រង្ស៊ី នឹងមានវិធានការបែបណាដែរ ដើម្បីជម្រុញអោយរដ្ឋាភិបាលបញ្ចុះតម្លៃប្រេង ស្របទៅតាមទីផ្សារពិភពលោកនោះ ? លោក*សុន ឆ័យ* បានមានប្រសាសន៍ថា "*ជាគោលការណ៍យើងត្រូវតែអោយមានការឆ្លើយឆ្លងគ្នាពន្យល់គ្នាពីព្រោះនៅក្នុងស្ថានភាពនៃការគ្រប់គ្រងមួយដែលមិនមានការតាមដាន និងឱ្យមានការសួរដេញដោលនេះ គឺអ្នកកាន់អំណាចត្រូវគ្នាជាមួយនឹងឈ្មួញ គឺគេកាងការពារនិងកេងបំបាត់ ដោយតម្លើងតម្លៃខ្ពស់នេះដើម្បីផលប្រយោជន៍, ហើយយើង នឹងហែកកកាយការពិត ពីព្រោះបើយើងវិភាគដើម្បីឱ្យមានការតាមដាន និងត្រួតពិនិត្យមើលថាតើអ្នកណានៅពីក្រោយខ្នង នៃការជំរុញមិនឱ្យទម្លាក់តម្លៃប្រេង ទៅ*

**តទៅទំព័រ៣ ន**

**តមកពីទំព័រ១ ក**

**គណបក្សប្រជាជននឹងបន្តកាន់អំណាចនោះ ប្រជារាស្ត្រក៏បានចាប់ផ្តើមមានកង្វល់ខ្លាំងឡើងៗ ដូចជាការប្រឈមនឹងបញ្ហាអំពើពុករលួយជាពិសេសការរំលោភយកដីធ្លីពីសំណាក់ពួកអ្នកធំអាងអំណាច និងពួកអ្នកមានអាងលុយ។**

**ពេលនេះសូម្បីតែរដ្ឋាភិបាលអាណត្តិទី៤មិនទាន់កើតចេញជារូបរាងឱ្យ ហ៊ុន សែន ចេញមុខដើរផ្សព្វផ្សាយអួតខ្លួនថាជានាយករដ្ឋមន្ត្រីថ្មីនៅឡើយផងនោះ ក៏ការរំលោភយកដីធ្លី និងបទល្មើសបំផ្លិចបំផ្លាញធនធានរបស់ប្រទេសនៅបន្តយ៉ាងគគ្រឹកគគ្រេង ដូចជាការកាប់ និងដឹកជញ្ជូនឈើដែលបន្តកើតមាននៅខេត្តរតនគិរី។ សម្រាប់ត្រឹមតែផ្នែកបញ្ហាដីធ្លីក៏វាគ្រប់គ្រាន់នឹងបង្កើតទំងន់ដ៏ធំធេងឱ្យប្រជារាស្ត្រក្តៅក្រហាយពាសពេញប្រទេស ដូច្នេះការរងគ្រោះក៏បង្កើនជាកម្លាំងទឹកចិត្តរបស់ប្រជារាស្ត្រឈឺចាប់។ នេះហើយទើបបានជាការប្រមើលមើលឃើញថា បដិវត្តន៍ដីធ្លីនឹងផ្ទុះឡើងដោយសារតែការគ្រប់គ្រងប្រទេសរបស់រដ្ឋាភិបាលគណបក្សប្រជាជនបង្កើនបញ្ហាឆក់ប្លន់រំលោភយកដីធ្លីរបស់ប្រជារាស្ត្របន្ថែមពីការយកដីធ្លីរបស់រដ្ឋទៅប្រគល់ឱ្យឈ្មួញ។**

**បញ្ហានេះលោក សុន ឆ័យ តំណាងរាស្ត្រនៃគណបក្សសមរង្ស៊ីក៏បានធ្វើការកត់សម្គាល់ថា គិតតាមទំហំនៃការរីកធំឡើងនូវបទល្មើសរំលោភប្លន់យកដីធ្លីរបស់ប្រជារាស្ត្រប្រព្រឹត្តដោយពួកអ្នកធំ និងពួកអ្នកមានជាខ្សែរយៈបក្ខពួករបស់គេនោះ ប្រាកដជាថ្ងៃណាមួយបដិវត្តន៍ដីធ្លីនឹងផ្ទុះឡើង។ គឺជាការនិយាយសំដៅដល់ការក្តៅក្រហាយរបស់ប្រជារាស្ត្ររងគ្រោះពីការរំលោភយកដីធ្លី ហើយក៏ផ្ទុះចេញទៅជាកំហឹងទាមទារឱ្យមានការកែប្រែជាបន្ទាន់នូវរបៀបគ្រប់គ្រងដីធ្លីនៅប្រទេសកម្ពុជា។**

**ការកត់សម្គាល់នេះក៏ស្របគ្នានឹងអ្វីដែលប្រេសិតពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិជាហូរហែបានធ្វើការថ្លឹងថ្លែងនូវមូលដ្ឋាននៃហេតុការណ៍ជាក់ស្តែងពីទំហំនៃបញ្ហា។ តាំងតែពីសម័យតំណាងជាន់ខ្ពស់នៃអគ្គលេខាធិការអង្គការសហប្រជាជាតិជាហូរហែ រហូតដល់លោក យ៉ាសហ្គាយ ថ្មីៗនេះ សុទ្ធតែមើលឃើញនូវទំហំនៃបញ្ហារំលោភយកដីធ្លីថា នឹងបំផ្ទុះឱ្យមានបដិវត្តន៍ដីធ្លី ឬការបះបោររបស់ប្រជារាស្ត្រទូទាំងប្រទេស នៅក្នុងប្រទេសកម្ពុជា ជាប្រទេសកសិកម្មដែលមានប្រជារាស្ត្រជាង៧០ភាគរយជាកសិករ។**

**រឿងរ៉ាវនេះក៏មានការព្រមានទុកដោយព្រះរាជសារជាព្រះរាជបន្ទូលរបស់អតីតព្រះមហាក្សត្រខ្មែរដែលរំលឹកឡើងថា បើមិនមានការដោះស្រាយបញ្ហារំលោភយកដីធ្លីដើម្បីឱ្យប្រជារាស្ត្រលែងបន្តរងគ្រោះយ៉ាងអយុត្តិធម៌នោះទេកម្ពុជាអាចនឹងជួបប្រទះនូវបដិវត្តន៍របស់កសិករដូចបដិវត្តន៍ដីធ្លី។ នោះគឺជាបញ្ហាដ៏ធំធេង និងជាគ្រោះថ្នាក់សម្រាប់កម្ពុជាដែលកើតឡើងជាផលវិបាកនៃការគ្រប់គ្រងប្រទេសយ៉ាងអនាធិបតេយ្យរបស់គណបក្សប្រជាជន ហ៊ុន សែន ក្នុងការប្លន់យកមិនត្រឹមតែទ្រព្យសម្បត្តិដីធ្លីរដ្ឋ ប៉ុន្តែក៏ថែមទាំងរឹបអូសយកដីធ្លីរបស់ប្រជារាស្ត្របំពេញមហិច្ឆតារបស់ពួកគេ។**

**ប្រជារាស្ត្រសព្វថ្ងៃ ជាពិសេសនៅក្រោយការបោះឆ្នោតនេះ ដែលខ្លះបានទាំងសុខចិត្តយល់ព្រមជឿគណបក្សប្រជាជនជាចុងក្រោយបោះឆ្នោតឱ្យគណបក្សនេះក្នុងសេចក្តីសង្ឃឹមថានឹងមានការដោះស្រាយបញ្ហាដីធ្លីជូនពួកគាត់នោះ ដល់ទីបំផុតពួកគាត់ក៏បានដឹងថា នោះគឺជាការចាញ់បោកគណបក្សប្រជាជន ហ៊ុន សែន។ ហើយការឈឺចាប់របស់ប្រជារាស្ត្រដែលជាអតីតសមាជិកគណបក្សប្រជាជននោះ ក៏បានបញ្ជាក់អំពីទំហំរីករាលដាលនៃបញ្ហាដីធ្លី និងការក្តៅក្រហាយរបស់ប្រជារាស្ត្រពាសពេញប្រទេស។ ប្រជារាស្ត្រនៅទីណាៗក៏ព្ទតែស្រែកថា ពួកគាត់ពុំមានជំនឿលើការដឹកនាំរដ្ឋាភិបាលថ្មីដោយ ហ៊ុន សែន នឹងអាចដោះស្រាយបញ្ហាដីធ្លីដោយយុត្តិធម៌ជូនពួកគាត់ជាម្ចាស់ដីធ្លីដែលត្រូវគេរំលោភយកនោះឡើយ។**

**គណបក្សប្រជាជន ហ៊ុន សែន ខ្លួនឯងក៏ពុំបានបង្ហាញអ្វីជាសកម្មភាពជាក់ស្តែងក្នុងបំណងឱ្យច្បាស់ថា នឹងដោះស្រាយបញ្ហានៃការរំលោភយកដីធ្លីលែងឱ្យប្រជារាស្ត្របន្តរងគ្រោះពីការប្លន់យកដីធ្លី ស្រែចំការ ផ្ទះសម្បែងពីសំណាក់ពួកអ្នកធំ និងពួកក្រុមហ៊ុនទាំងឡាយនោះទេ។ នេះពីព្រោះតែ ហ៊ុន សែន ក៏ធ្លាប់បាននិយាយអំពីរបស់ដែលហៅថាសិល្បៈនៃការចែករំលែក ជាការសំដៅដល់ការបែងចែករំលែកផលប្រយោជន៍ដែលពួកគេអាចរកបានពីទ្រព្យសម្បត្តិធនធានរបស់ប្រទេស ក៏ដូចជាដីធ្លីរបស់ប្រជារាស្ត្រនោះហើយ។**

**បដិវត្តន៍ដីធ្លីពោលគឺជាការក្តៅក្រហាយរបស់ប្រជារាស្ត្រដែលរងគ្រោះនឹងការឈឺចាប់ចំពោះការប្លន់រំលោភយកដីធ្លីហើយគណបក្សកាន់អំណាច ពោលគឺគណបក្សប្រជាជន ហ៊ុន សែន មិនបានដោះស្រាយ។ នេះគឺជាបញ្ហាដែលនឹងបង្កើតជាគ្រោះថ្នាក់ដល់កម្ពុជា ក្នុងពេលដែលគណបក្សប្រជាជន ហ៊ុន សែន នៅតែបន្តបើកដៃឱ្យជនអន្តោប្រវេសន៍យួនខុសច្បាប់ក្នុងចំនួនរាប់លាននាក់ចូលពាសពេញប្រទេសកម្ពុជា។ បន្ថែមពីលើនេះទៅទៀតគឺរដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន បានទាំងយកដីរដ្ឋ ពេលខ្លះប្រមូលដោយទាំងដីរាស្ត្រទៅផ្តល់ជាសម្បទានសេដ្ឋកិច្ចឱ្យក្រុមហ៊ុនយួនពង្រីករបស់ដែលហៅថា ដំណាំចំការកៅស៊ូរាប់សែនហិកតាពេលដែលប្រជារាស្ត្រខ្មែរខ្វះដីធ្លី និងរស់នៅលំបាកវេទនាក្នុងជីវភាពខ្សត់ខ្សោយ ក្រីក្រនោះ។**

**ប្រជារាស្ត្រមិនជឿថា គណបក្សប្រជាជន ហ៊ុន សែន ដែលនឹងមានឱកាសឡើងកាន់អំណាចជាថ្មីទៀតនឹងមានមារយាទចេះដោះស្រាយបញ្ហាដីធ្លីជូនប្រជារាស្ត្រឱ្យមានយុត្តិធម៌ និងសមធម៌ កុំឱ្យប្រជារាស្ត្របន្តរងគ្រោះបាត់បង់ដីធ្លី និងរស់ក្នុងជីវភាពលំបាកវេទនាដូចសព្វថ្ងៃនេះនោះទេ៕**